ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ : ០៤ ប្រកាស

សេចក្តីប្រកាសព័ត៌មាន
ស្តីពី
លទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី
ថ្ងៃសុក្រ ២កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ត្រូវនឹងថ្ងៃទី៨ ខែតុលា ឆ្នាំ២០២១

នៅព្រឹកថ្ងៃសុក្រ ២កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៨ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង៨និង២០នាទីព្រឹក នៅវិមានសន្តិភាព ទីស្តីការគណៈរដ្ឋមន្ត្រី មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យនិងពិភាក្សាលើ៖

១-សេចក្តីព្រាងច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា១៩ថ្មី មាត្រា៨២ថ្មី មាត្រា១០៦ថ្មី(មួយ) មាត្រា១១៩ថ្មី និងមាត្រា១៣៧ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និង មាត្រា៣និងមាត្រា៤ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការប្រក្រតីនៃស្ថាប័នជាតិ។

២-សេចក្តីព្រាងច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន។

៣-សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០២២-២០២៤។

៤-បញ្ហាផ្សេងៗ៖ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ លើសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងបន្ថែមទៅលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិទាក់ទងទៅនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ស្តីពីការរៀបចំក្នុងពេលអន្តរកាល និងការបញ្ចប់ការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ។

ក្រោយពីបានស្តាប់របាយការណ៍និងមតិពិភាក្សាផ្លាស់ប្តូរយោបល់រួចមក សម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានសម្រេចអនុម័ត៖

១-សេចក្តីព្រាងច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា១៩ថ្មី មាត្រា៨២ថ្មី មាត្រា១០៦ថ្មី(មួយ) មាត្រា១១៩ថ្មី និងមាត្រា១៣៧ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និង មាត្រា៣ និងមាត្រា៤ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការប្រក្រតីនៃស្ថាប័នជាតិ

រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងក្រុមប្រឹក្សាធម្មនុញ្ញ គឺជាស្ថាប័នកំពូលរបស់ជាតិ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមានការទទួលខុសត្រូវក្នុងការសម្រេចលើកិច្ចការសំខាន់ៗដែលជាអាយុជីវិតរបស់ប្រទេសជាតិ សំដៅធានាការពារឯករាជ្យជាតិ អធិបតេយ្យជាតិ និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ឧត្តមប្រយោជន៍ជាតិនិងប្រជាជនកម្ពុជា និងការប្រឆាំងដាច់ខាតនឹងការជ្រៀតជ្រែកពីបរទេសចូលក្នុងកិច្ចការផ្ទៃក្នុងរបស់ជាតិ ឬការបង្គាប់បញ្ជាចំពោះគោលនយោបាយជាតិនិងអន្តរជាតិរបស់កម្ពុជា។ ផ្អែកលើមូលដ្ឋាននេះ ប្រធានរដ្ឋសភា ប្រធានព្រឹទ្ធសភា នាយករដ្ឋមន្ត្រី និងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ សុទ្ធតែត្រូវបានកំណត់ឱ្យមានកាតព្វកិច្ចត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង នៅចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រ ព្រះភ័ក្ត្រនៃសម្តេចព្រះសង្ឃរាជ និងទេវតារក្សាស្វេតច្ឆត្រ ដោយត្រូវសច្ចាប្តេជ្ញាជាដាច់ខាតក្នុងការអនុវត្តកាតព្វកិច្ចស្មោះត្រង់ចំពោះជាតិ និងការការពារឧត្តមប្រយោជន៍ ដែលជាអាយុជីវិតរបស់ជាតិ និងប្រជាជនកម្ពុជា។

ទន្ទឹមនេះ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ដែលមានការពាក់ព័ន្ធ ក៏បានតម្រូវឱ្យតំណាងរាស្ត្រ សមាជិកព្រឹទ្ធសភា នាយករដ្ឋមន្ត្រី និងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំងអស់ត្រូវតែមានសញ្ជាតិខ្មែរតាំងពីកំណើត។ បន្ថែមពីនេះ ប្រធាន អនុប្រធាន និងសមាជិកទាំងអស់នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលជាស្ថាប័នមានចែងក្នុងរដ្ឋធម្មនុញ្ញផងដែរនោះ ក៏ត្រូវបានច្បាប់កំណត់ឱ្យត្រូវតែមានសញ្ជាតិខ្មែរពីកំណើត និងមានសញ្ជាតិខ្មែរតែមួយគត់ ដើម្បីធានាឱ្យការបំពេញភារកិច្ចរបស់ខ្លួនទាក់ទងនឹងការងារបោះឆ្នោត ដែលជាស្នូលនៃដំណើរការប្រជាធិបតេយ្យសេរីពហុបក្សនៅកម្ពុជា ប្រព្រឹត្តទៅដោយឯករាជ្យ ដើម្បីធានាការពារឧត្តមប្រយោជន៍ជាតិពីការជ្រៀតជ្រែកចូលក្នុងកិច្ចការផ្ទៃក្នុង ទាក់ទងនឹងកិច្ចដំណើរការបោះឆ្នោតពីខាងក្រៅ។

ដើម្បីធានាបានឱកាសភាពទាំងខាងផ្លូវច្បាប់ ទាំងខាងនយោបាយ ចំពោះគោលជំហរនិងការប្តេជ្ញាចិត្តស្មោះត្រង់ឥតងាករេចំពោះជាតិ មាតុភូមិ និងប្រជាជនកម្ពុជានៅគ្រប់កាលៈទេសៈទាំងអស់ និងដើម្បីធានាការពារឧត្តមប្រយោជន៍របស់ជាតិនិងប្រជាជនកម្ពុជា ពីការជ្រៀតជ្រែកពីបរទេស និងដោយយោងតាមមាត្រា១៥៣ថ្មី(ពីរ) នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលបានស្នើធ្វើវិសោធនកម្មមាត្រា១៩ថ្មី មាត្រា៨២ថ្មី មាត្រា១០៦ថ្មី(មួយ) មាត្រា១១៩ថ្មី និងមាត្រា១៣៧ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និង មាត្រា៣និងមាត្រា៤ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ សំដៅចារឹកគោលការណ៍គ្រឹះទាំងនេះចូលទៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលជាច្បាប់គ្រឹះ និងជាច្បាប់កំពូលរបស់ជាតិ ដោយកំណត់ឱ្យប្រធានរដ្ឋសភា ប្រធានព្រឹទ្ធសភា នាយករដ្ឋមន្ត្រី និងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវតែជាឥស្សរជនដែលមាន«**សញ្ជាតិខ្មែរតែមួយគត់**»។

សេចក្តីព្រាងច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា១៩ថ្មី មាត្រា៨២ថ្មី មាត្រា១០៦ថ្មី(មួយ) មាត្រា១១៩ថ្មី និងមាត្រា១៣៧ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និង មាត្រា៣និងមាត្រា៤ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ មានចំនួនបីមាត្រា ហើយត្រូវបានសម្រេចឯកភាពដោយអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។

២-សេចក្តីព្រាងច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន

សេចក្តីព្រាងច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន (ភ.រ.ជ.) ត្រូវបានរៀបចំឡើងដោយឈរលើមូលដ្ឋាននៃ «ឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការ ភ.រ.ជ. សម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០» ដែលរាជរដ្ឋាភិបាលបានអនុម័តកាលពីខែមិថុនា ឆ្នាំ២០១៦ កន្លងទៅ។ ក្នុងចំណោមវិធានការគោលនយោបាយគន្លឹះៗដែលបានដាក់ចេញក្នុងឯកសារគោលនយោបាយនេះ សេចក្តីព្រាងច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន (ភ.រ.ជ.) ត្រូវបានរៀបចំឡើងដើម្បីជំនួស ច្បាប់ស្តីពីសម្បទាន បន្ទាប់ពីច្បាប់នេះត្រូវបានពិនិត្យឡើងវិញនិងវាយតម្លៃឃើញថាមិនទាន់អនុលោមពេញលេញតាមឧត្តមានុវត្តន៍អន្តរជាតិនិងសភាពការណ៍ជាក់ស្តែងនៃការគ្រប់គ្រងនិងអនុវត្តគម្រោង ភ.រ.ជ. បាននៅឡើយ ជាពិសេសពាក់ព័ន្ធទៅនឹងបញ្ហាស្ថាប័នមានសមត្ថកិច្ច ទម្រង់នៃការទូទាត់ កិច្ចធានារបស់រដ្ឋ សិទ្ធិនិងកាតព្វកិច្ចមួយចំនួនរបស់គូភាគីនៃកិច្ចសន្យា ភ.រ.ជ. និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការគម្រោង ជាដើម។

សេចក្តីព្រាងច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន (ភ.រ.ជ.) ត្រូវបានរៀបចំឡើងក្នុងបរិការណ៍ៈ (១) ការថយចុះហិរញ្ញប្បទានឥតសំណងលើសកលលោក និងការបាត់បង់បណ្តើរៗនូវឥណទានសម្បទានកម្រិតខ្ពស់របស់កម្ពុជានាពេលអនាគត, (២) វិបត្តិជំងឺកូវីដ-១៩ កំពុងយាយីនិងបង្កផលប៉ះពាល់អវិជ្ជមានដល់សមិទ្ធផលសង្គម-សេដ្ឋកិច្ច ដែលកម្ពុជាសម្រេចបាននាពេលកន្លងមក និងបន្ទច់បង្អាក់ដល់ដំណើរការឈានឡើងរបស់កម្ពុជា ជាពិសេស អាចនឹងពន្យារពេលនៃការឈានទៅសម្រេចបាននូវចក្ខុវិស័យរបស់កម្ពុជា ក្នុងការប្រែក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០, (៣) កិច្ចខិតខំប្រឹងប្រែងក្នុងការបញ្ចៀសកម្ពុជាកុំឱ្យធ្លាក់ជុងទៅក្នុង «អន្ទាក់នៃថ្លៃ» ដែលអាចកើតមានឡើងតាមរយៈការចុះកិច្ចសន្យាដែលមានរយៈពេលវែង ដោយមិនមានការពិនិត្យនិងវាយតម្លៃត្រឹមត្រូវនិងហ្មត់ចត់, និង (៤) ការជំរុញកំណើននិងការរក្សាជវភាពសេដ្ឋកិច្ចកម្ពុជា ដោយផ្អែកលើមូលដ្ឋានប្រភពធនធាននិងវានុវត្តន៍ពីវិស័យឯកជន ក្នុងការចូលរួមអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងការផ្តល់សេវាសាធារណៈ។

សេចក្តីព្រាងច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន (ភ.រ.ជ.) មានគោលបំណងលើកកម្ពស់ការគ្រប់គ្រងយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន នៅក្នុងការរៀបចំនិងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈនិងគម្រោងសេវាសាធារណៈ សំដៅពង្រឹងភាពប្រកួតប្រជែងសេដ្ឋកិច្ចកម្ពុជាក្នុងតំបន់និងសកលលោក ដើម្បីជាឧត្តមប្រយោជន៍ដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមនៅកម្ពុជា និងបង្កើនភាពទាក់ទាញដល់វិស័យឯកជន ស្របតាមឧត្តមានុវត្តន៍អន្តរជាតិនិងបរិការណ៍ជាក់ស្តែងរបស់កម្ពុជា។ តាមរយៈសេចក្តីព្រាងច្បាប់នេះ រំពឹងថានឹងផ្តល់នូវអត្ថប្រយោជន៍គន្លឹះចំនួនពីរ គឺ ទី១ ការពង្រីកលម្ហហិរញ្ញវត្ថុសាធារណៈ និង ទី២ ការជំរុញប្រសិទ្ធភាពនិងវានុវត្តន៍នៃការរៀបចំអភិវឌ្ឍនិងអនុវត្តគម្រោងរបស់វិស័យឯកជន។

សេចក្តីព្រាងច្បាប់នេះ ត្រូវបានគាក់តែងឡើងដោយមិនឱ្យមានអានុភាពប្រតិសកម្មចំពោះកិច្ចព្រមព្រៀងសម្បទានឬកិច្ចសន្យាដែលមានលក្ខណៈប្រហាក់ប្រហែលនឹងកិច្ចសន្យា ភ.រ.ជ. ដែលបានចុះហត្ថលេខាមុនច្បាប់នេះចូលជាធរមាននោះទេ។ ជាមួយគ្នានេះ សេចក្តីព្រាងច្បាប់នេះមិនមានអានុភាពអនុវត្តចំពោះគម្រោងអាទិភាពនានាដែលទទួលបានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាលនោះឡើយ។

សេចក្តីព្រាងច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន ត្រូវបានរៀបចំឡើងដោយមាន១៤ជំពូក ៤៩មាត្រា និង២ឧបសម្ព័ន្ធ ហើយត្រូវបានសម្រេចឯកភាពដោយអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។

៣-សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០២២-២០២៤

សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ (ក.វ.ស.) ៣ឆ្នាំរំកិល ២០២២-២០២៤ មានគោលបំណងបង្ហាញពីទិន្នន័យគម្រោងវិនិយោគដែលមានអាទិភាពខ្ពស់របស់ក្រសួងស្ថាប័ន ដែលជាគោលនយោបាយមានចែងក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភា និងជាផែនទីចង្អុលផ្លូវសម្រាប់ការអនុវត្តគោលនយោបាយដែលមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០១៩-២០២៣។

សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ (ក.វ.ស.) ៣ឆ្នាំរំកិល ២០២២-២០២៤ បានដាក់បញ្ចូលគ្នានូវគម្រោងកំពុងដំណើរការ ដែលការអនុវត្តគម្រោងកំពុងបន្តនៅក្នុងដំណាក់កាល ក.វ.ស. និងគម្រោងសម្រាប់អនុវត្ត ផ.យ.អ.ជ. ដែលជាគម្រោងស្នើសុំថ្មីត្រូវអនុវត្តក្នុងដំណាក់កាល ក.វ.ស.។ ចំពោះ ក.វ.ស. ៣ឆ្នាំរំកិល ២០២២-២០២៤ នេះ មានគម្រោងសរុប៦៧៣ ដោយក្នុងនោះ ១៨៥គម្រោង គឺជាគម្រោងកំពុងដំណើរការ ដែលត្រូវការទុនចំនួន៥ ៨១៧លានដុល្លារអាម៉េរិក និង ៤៨៨គម្រោង ជាគម្រោងសម្រាប់អនុវត្ត ផ.យ.អ.ជ. ឬគម្រោងថ្មី ដែលត្រូវការទុនចំនួន៣ ៣៨៤លានដុល្លារអាម៉េរិក។

បរិមាណទុនសរុបនៃ ក.វ.ស. ៣ឆ្នាំរំកិល ២០២២-២០២៤ មានចំនួន៩ ២០១លានដុល្លារអាម៉េរិក ក្នុងនោះ បរិមាណទុនដែលបានសន្យាផ្តល់ដោយរាជរដ្ឋាភិបាលកម្ពុជានិងដៃគូអភិវឌ្ឍរួចហើយមានចំនួន៧ ៧១៣,៣លានដុល្លារអាម៉េរិក (ពីរាជរដ្ឋាភិបាលកម្ពុជាមានចំនួន៥៧៧,១លានដុល្លារអាម៉េរិក និងពីដៃគូអភិវឌ្ឍមានចំនួន៧ ២៣៦,២លានដុល្លារអាម៉េរិក) ដោយត្រូវការទុនបន្ថែមចំនួន ១ ៤៨៧,៧លានដុល្លារអាម៉េរិក។

ការវិភាជទុនដល់គម្រោងនានារបស់ ក.វ.ស. ៣ឆ្នាំរំកិល ២០២២-២០២៤ ទៅតាមវិស័យនីមួយៗ ត្រូវបានកំណត់៖ វិស័យសង្គមកិច្ច(១១,៨%) វិស័យសេដ្ឋកិច្ច(៣៧,៦%) វិស័យហេដ្ឋារចនាសម្ព័ន្ធ (៥៤,២%) និង វិស័យសេវាកម្មនិងកម្មវិធីអន្តរវិស័យ(៦,៤%)។

សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ (ក.វ.ស.) ៣ឆ្នាំរំកិល ២០២២-២០២៤ ត្រូវបានរៀបចំឡើងដោយចែកចេញជា៤ជំពូក មានបញ្ជីតារាងចំនួន១២និងឧបសម្ព័ន្ធចំនួន១ ហើយត្រូវបានសម្រេចឯកភាពដោយអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។

៤-បញ្ហាផ្សេងៗ៖

៤.១. អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានអនុម័តបញ្ជូន «សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងបន្ថែមទៅលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិទាក់ទងទៅនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ស្តីពីការរៀបចំក្នុងពេលអន្តរកាល និងការបញ្ចប់ការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ» ទៅសុំការអនុម័តយល់ព្រមពីស្ថាប័ននីតិប្បញ្ញត្តិ។

៤.២. សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៍ថា៖

- ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនិងច្បាប់ធម្មនុញ្ញបន្ថែមដោយកំណត់ឱ្យប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី និងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវមានសញ្ជាតិខ្មែរតែមួយគត់ គឺដើម្បីផលប្រយោជន៍រយៈពេលវែងសម្រាប់ប្រទេសកម្ពុជា បង្ហាញនូវការជ្រៀតជ្រែកពីបរទេស និងបង្ហាញភក្តីភាពចំពោះជាតិមាតុភូមិ

- ប្រទេសសាយប្រឹស(Cyprus) និងកម្ពុជា សុទ្ធតែជារដ្ឋរងគ្រោះពីការចេញផ្សាយខុសពីការពិតពាក់ព័ន្ធនឹងការផ្តល់សញ្ជាតិដល់ សម្តេចតេជោនាយករដ្ឋមន្ត្រី ពីសំណាក់សារព័ត៌មានអង់គ្លេស The Guardian។ ដ្បិតថាសារព័ត៌មានបានកែហើយក្តី សម្តេចតេជោ បានបញ្ជារដ្ឋមន្ត្រីការបរទេស និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឱ្យធ្វើការបញ្ជាក់ជាមួយរដ្ឋមន្ត្រីប្រទេសសាយប្រឹស(Cyprus) ដើម្បីបញ្ចប់នូវការភ័ន្តច្រឡំ ព្រោះបញ្ហានេះជារឿងធំដែលពាក់ព័ន្ធករណីមេដឹកនាំជាតិមួយត្រូវបានគេមូលបង្កាច់

- កម្ពុជាទទួលបានមោទនភាពដោយសម្រេចបានអត្រាខ្ពស់នៃអ្នកចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដែលគិតមកត្រឹមពេលនេះគឺមានចំនួន៨៤,៨១% នៃចំនួនប្រជាជនសរុប ដែលក្នុងនោះ កុមារអាយុ៦-១២ឆ្នាំ សម្រេចបាន៩៣,៧៨% កុមារអាយុ១២-១៨ឆ្នាំ សម្រេចបាន៨៩,៦៨% និងប្រជាជនអាយុ១៨ឆ្នាំឡើង សម្រេចបាន៩៩,១៤%។ រាជរដ្ឋាភិបាលប្តេជ្ញាបន្តជំរុញការចាក់វ៉ាក់សាំងឱ្យបានកាន់តែឆាប់និងសម្រេចតាមផែនការ ដើម្បីបង្កើតភាពស៊ាំក្នុងសហគមន៍ និងឈានដល់ការបើកដំណើរការឡើងវិញនូវវិស័យទេសចរណ៍ផ្ទៃក្នុងនិងវិស័យសេដ្ឋកិច្ច-សង្គមដែលបានជាប់គាំងនាពេលកន្លងមក

- ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ មិនត្រឹមតែជួយការពារសុខភាព ការពារអាយុជីវិតពីការឃាឃីមេរោគកូវីដ-១៩ប៉ុណ្ណោះទេ តែទៅថ្ងៃមុខ ការចាក់វ៉ាក់សាំងនឹងក្លាយទៅជាវ៉ាក់សាំងកាតព្វកិច្ចនិងជាតម្រូវការចាំបាច់ពាក់ព័ន្ធនឹងការរស់នៅប្រចាំថ្ងៃផងដែរ

- អាជ្ញាធរពាក់ព័ន្ធត្រូវខិតខំបន្តស្រាវជ្រាវរកអ្នកមិនទាន់ចាក់វ៉ាក់សាំង ព្រមទាំងក្រុមប្រឆាំងនិងអ្នកដែលជឿតាមការឃោសនារបស់ក្រុមប្រឆាំង ឱ្យនាំគ្នាទៅចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩។ សម្តេចតេជោ បានថ្លែងថាសម្តេចមិនចង់ឃើញក្រុមប្រឆាំងទាំងនោះត្រូវស្លាប់ដោយសារជំងឺកូវីដ-១៩ ព្រោះតែការមិនបានចាក់វ៉ាក់សាំងនោះឡើយ

- សម្តេចតេជោនាយករដ្ឋមន្ត្រី ចូលរួមអបអរសាទរដល់អភិបាលនៃគណៈអភិបាលខេត្តទាំងឡាយដែលទើបទទួលបានការតែងតាំងឱ្យបំពេញភារកិច្ចថ្មី

- គ្រូបង្រៀន សាស្ត្រាចារ្យ និងបុគ្គលិកអប់រំនៅទូទាំងប្រទេស ត្រូវចាក់វ៉ាក់សាំងកូវីដ-១៩ ឱ្យបានរួចរាល់និងត្រឹមត្រូវ ទើបអាចអនុញ្ញាតឱ្យចូលបំពេញការងារបាន។ រាល់ការចូលក្នុងបរិវេណគ្រឹះស្ថានសិក្សា ត្រូវមានបណ្ណចាក់វ៉ាក់សាំងភ្ជាប់មកជាមួយ ដើម្បីទប់ស្កាត់ហានិភ័យនៃការរីករាលដាលជំងឺកូវីដ-១៩

- រាជរដ្ឋាភិបាល ប្តេជ្ញាបញ្ចប់បញ្ហារថយន្តមិនបង់ពន្ធនិងអាករនាំចូល និងរថយន្តចង្កូតស្តាំខុសច្បាប់ ដែលជាបញ្ហាច្រំដែល ចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ តទៅ៖

ទី១-អនុវត្តឱ្យបានម៉ឺងម៉ាត់តាមសេចក្តីជូនដំណឹងលេខ៥៤២ សជណ.ហជ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីការអនុវត្តវិធានការលើការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ប្រចាំឆ្នាំ២០២១ ជាលើកចុងក្រោយចំពោះយានយន្តឯកជនដែលជ្រោកក្រោមផ្លាកលេខក្រសួង ស្ថាប័នរដ្ឋ ជាពិសេសផ្លាកលេខ ខ.ម និង ន.ប ដើម្បីឱ្យម្ចាស់ចូលខ្លួនមកបំពេញកាតព្វកិច្ចពន្ធនិងអាករនាំចូលស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីគយ។

ទី២-ចំពោះម្ចាស់រថយន្តឯកជនជ្រកក្រោមផ្លាកលេខរដ្ឋ ផ្លាកលេខ ខ.ម និង ន.ប ដែលមានចង្កូតឆ្វេង និងពុំមានក្នុងបញ្ជីទ្រព្យរដ្ឋរបស់អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរួសរាន់ចូលមកមង្គលពន្ធនិងអាករឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ដើម្បីទទួលបានការអនុគ្រោះបន្ទុបន្ទយ

ពន្ធនៃប្រាក់ពន្ធអាករសរុបពី១០០% មកត្រឹមតែ៩០%។ ប៉ុន្តែចំពោះរថយន្តទំនើបដែលទើបនាំចូលក្នុងឆ្នាំ២០២១ ត្រូវបង់ពន្ធនិងអាករ១០០%ដដែល។ ប្រសិនជាម្ចាស់យានយន្តមិនបានបំពេញកាតព្វកិច្ចបង់ពន្ធនិងអាករនោះទេ គឺក្រោយថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ នឹងត្រូវយកពន្ធនិងអាករពេញ១០០% ព្រមទាំងត្រូវទទួលរងការផាកពិន័យទៀត។

ទី៣-ចំពោះម្ចាស់រថយន្តចង្កូតស្តាំទាំងអស់ ត្រូវរួសរាន់មកបង់ប្រាក់ពន្ធអាករ ហើយទទួលបានការអនុគ្រោះបន្ទុរបន្ថយពន្ធចំនួន១០%ដែរ និងត្រូវយករថយន្តទៅកែចង្កូតឱ្យបានរួចរាល់មុនថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២។ ចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ តទៅ មិនអនុញ្ញាតឱ្យរថយន្តឯកជនដែលមានចង្កូតស្តាំធ្វើដំណើរលើផ្លូវសាធារណៈទៀតនោះឡើយ លើកលែងតែរថយន្តចង្កូតស្តាំមួយចំនួនដែលមានការអនុញ្ញាតពីរាជរដ្ឋាភិបាលជាលក្ខណៈពិសេស ដូចជារថយន្តសង្គ្រោះបន្ទាន់ រថយន្តពន្លត់អគ្គីភ័យ រថយន្តដឹកសំរាមជាដើម។

ទី៤-ចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ តទៅ អាជ្ញាធរដែនដីនិងកងកម្លាំងប្រដាប់អាវុធ ត្រូវសហការជាមួយគ្នា ដើម្បីបង្កើនសកម្មភាពទប់ស្កាត់និងបង្ក្រាបរថយន្តគ្មានពន្ធ។ ក្នុងករណីចាំបាច់ ប្រសិនបង្ក្រាបបានរថយន្តសេរីទំនើបគ្មានពន្ធដែលម្ចាស់ជាមេទ័ពមេប៉ូលីស ឬជាអ្នកធំក្នុងជួររាជរដ្ឋាភិបាល តំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភា ជាដើមដែលមិនគោរពច្បាប់និងបន្តប្រើប្រាស់រថយន្តនោះ ត្រូវរាយការណ៍អំពីអត្តសញ្ញាណម្ចាស់រថយន្តជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដើម្បីសម្តេចមានវិធានការដកមុខតំណែង និងបណ្តេញចេញពីគណបក្សថែមទៀត។

ទី៥-ទាំងអស់គ្នាត្រូវចូលរួមអនុវត្តច្បាប់ឱ្យបានម៉ឺងម៉ាត់។ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២២ តទៅ រថយន្តគ្មានពន្ធនិងអាករមិនអាចចរាចរលើដងផ្លូវបានឡើយ គឺជារថយន្តខុសច្បាប់ដែលនឹងត្រូវរងវិធានការយ៉ាងតឹងរ៉ឹងនិងម៉ឺងម៉ាត់បំផុត។

- **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណដល់អាជ្ញាធរពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ ព្រមទាំងកងកម្លាំងប្រដាប់អាវុធ ដែលបានយកចិត្តទុកដាក់ខ្ពស់រក្សាសន្តិសុខសណ្តាប់ធ្នាប់ និងទប់ស្កាត់ការឆ្លងជំងឺកូវីដ-១៩ ជូនប្រជាពលរដ្ឋក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ។ **សម្តេចតេជោ** ក៏ថ្លែងអំណរគុណដល់ប្រជាពលរដ្ឋគ្រប់រូបដែលមានភាពម្ចាស់ការ និងបានស្ម័យការពារខ្លួនពីគ្រោះថ្នាក់ចរាចរណ៍ ពិសេសប្រកាន់ខ្ជាប់នូវវិធានការ «៣កុំ ៣ការពារ» និងវិធានការនានារបស់ក្រសួងសុខាភិបាល ដើម្បីបង្ការការចម្លងជំងឺកូវីដ-១៩។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង១១និង១៩នាទី។

ថ្ងៃសុក្រ ២កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី៨ ខែតុលា ឆ្នាំ២០២១